## រឿងទី៣៖ ព្រះយេស៊ូស្រឡាញ់ក្មេងៗ

**ខគម្ពីរ៖ ម៉ាថាយ១៩:១៤**

នោះព្រះយេស៊ូវទ្រង់មានព្រះបន្ទូលថា ទុកឲ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរស្ថានសួគ៌មានសុទ្ធតែមនុស្សដូចវារាល់គ្នា

ព្រះយេស៊ូបានយាងមកដល់ភូមិយូដាជាមួយពួកសិស្ស ដើម្បីផ្សាយដំណឹងល្អពីនគរព្រះជាម្ចាស់។

គ្រប់កន្លែងដែលព្រះយេស៊ូយាងទៅ តែងតែមានមនុស្សមកប្រមូលផ្តុំគ្នាយ៉ាងច្រើន។

ហើយក្នុងនោះ ក៏មានឪពុកម្តាយដែលបាននាំកូនៗមកជាមួយផងដែរ។

ក្មេងៗសប្បាយចិត្តខ្លាំងណាស់ ដោយព្រោះគិតថាបានជួបព្រះយេស៊ូ!

ពួកគេបានឃើញព្រះយេស៊ូ!

ក្មេងៗបានរត់យ៉ាងលឿន ដើម្បីចូលទៅជិតព្រះយេស៊ូ។

ប៉ុន្តែ នៅពេលដែលក្មេងៗព្យាយាមទៅរកព្រះយេស៊ូ ស្រាប់តែពួកសិស្សបានឃាត់ក្មេងៗនិងឪពុកម្តាយពួកគេ

ព្រះយេស៊ូបានទតឃើញទិដ្ឋភាពនោះ ទ្រង់ក៏បានបន្ទោសពួកសិស្សថា៖

"ទុកឲ្យក្មេងៗមកឯខ្ញុំចុះ! កុំឲ្យឃាត់វាឡើយ! នគរស្ថានសួគ៌មានសុទ្ធតែមនុស្សដូចវារាល់គ្នាដែរ! ឱ ពួកសិស្សទាំងអស់គ្នាអើយ ខ្ញុំសូមប្រាប់អ្នករាល់គ្នាឲ្យដឹងច្បាស់ថា ចូរជឿលើនគរព្រះជាម្ចាស់ដូចជាក្មេងតូចនេះ! អ្នកណាមិនព្រមទទួលព្រះរាជ្យព្រះជាម្ចាស់ដូចក្មេងតូចមួយទេ អ្នកនោះចូលក្នុងព្រះរាជ្យព្រះអង្គមិនបានឡើយ។"

ព្រះយេស៊ូបានលាព្រះហស្តទាំងពីរទទួលក្មេងៗ។ ព្រះយេស៊ូបានឱបក្មេងៗ ហើយបានដាក់ព្រះហស្តប្រទានពរដល់ពួកគេ។

គ្រប់ទីកន្លែងដែលព្រះយេស៊ូយាងទៅ ទ្រង់តែងតែផ្តល់ក្តីស្រឡាញ់ដល់ក្មេងៗ ទ្រង់មិនធុញទ្រាន់នឹងពួកគេឡើយ។





**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។

a. ហេតុអ្វីបានជាព្រះយេស៊ូមានបន្ទូលប្រាប់ថាកុំឃាត់ក្មេងៗដែលមករកទ្រង់ដូច្នេះ?

-----------------------------------------------------------------------------------

b. តើព្រះយេស៊ូបានធ្វើអ្វីខ្លះចំពោះកុមារដែលមករកទ្រង់?

-----------------------------------------------------------------------------------

c. សូមអាន ម៉ាថាយ១៩៖១៣ រួចឆ្លើយសំណួរ។ នៅពេលដែលឪពុកម្ដាយបាននាំកូនៗមកព្រះយេស៊ូ តើពួកគេចង់ឱ្យទ្រង់ធ្វើអ្វី?

-----------------------------------------------------------------------------------

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (ម៉ាថាយ ១៩៖១៤)

**នោះព្រះយេស៊ូវទ្រង់មានព្រះបន្ទូលថា ទុកឱ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរស្ថានសួគ៌មានសុទ្ធតែមនុស្សដូចវារាល់គ្នា**

## សកម្មភាពទី២

ដើម្បីជួបព្រះយេស៊ូ តើក្មេងៗត្រូវជ្រើសរើសផ្លូវមួយណា?

សូមជ្រើសរើសលេខណាមួយ ក្នុងចំណោមលេខ1-10 ដែលនឹងនាំអ្នកទៅជួបព្រះយេស៊ូ។ ផ្លាស់ទីពីឆ្វេងទៅស្តាំ ហើយនៅពេលអ្នកជួបបន្ទាត់បញ្ឈរ សូមរំកិលឡើងលើ ឬចុះក្រោមរហូតដល់ជួបព្រះយេស៊ូ។

